# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ណែនាំក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្តកំពត ឲ្យបន្តយកចិត្តទុកដាក់ដោះស្រាយបញ្ហាកង្វល់ និងសំណូមពររបស់ប្រជាពលរដ្ឋ ឲ្យមានប្រសិទ្ធភាព




រៀបចំដោយៈ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

កំពត ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៦៖ **ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត នៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល២ខែ និងលើកទិសដៅអនុវត្តបន្តរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពត កាលពីព្រឹកថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៦ បានណែនាំដល់គ្រប់ក្រុមការងារថ្នាក់ជាតិ ខេត្ត ក្រុង ស្រុក នៃខេត្តកំពត ឱ្យបន្តយកចិត្តទុកដាក់ ពិនិត្យដោះស្រាយបញ្ហាកង្វល់ និងសំណូមពររបស់ប្រជាពលរដ្ឋ ឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ នៅចំពោះមុខសមាជិក សមាជិកានៃកិច្ចប្រជុំ ដែលមានសមាសភាពចម្រុះជាតំណាងមកពីក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រមាណជា ២០៤នាក់ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលដ៏ល្អនៃការបើកវេទិកាសាធារណៈរបស់ក្រុមការងារនៅថ្នាក់ក្រុង ស្រុកទាំង៨ របស់ខេត្តកំពត ដែលបានទទួលយកមកពិនិត្យ និងចាត់ចែងដោះស្រាយនូវរាល់សំណូមពរ ក៏ដូចជាបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ដែលបានលើកឡើងក្នុងអង្គ វេទិកាសាធារណៈ។ នៅក្នុងនេះ បញ្ហាដែលពាក់ព័ន្ធនឹងការងារអភិវឌ្ឍជនបទ ការងារសាធារណការ ការងារកសិកម្ម បរិស្ថាន ដូចជា ការធ្វើផ្លូវថ្នល់ ស្ពាន ការធ្វើទំនប់ទឹក ឬទំនប់ទប់ទឹកប្រៃ ការជីក ឬស្តារ ប្រឡាយ ស្រះទឹក ការជីកអណ្តូងទឹក គឺជាការងារអាទិភាព។

នៅក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអរគុណចំពោះរដ្ឋបាលខេត្ត ដែលបានរៀបចំសម្រួលឲ្យប្រជាពលរដ្ឋ បានធ្វើដំណើរដោយមធ្យោបាយធុនតូច ដូចជា ម៉ូតូ កង់ ឆ្លងកាត់តាមស្ពានចាស់ ក្រុងកំពត ដែលកន្លងទៅបានផ្អាកមួយរយៈដោយបញ្ហាទ្រុឌទ្រោម។ នេះគឺជាការអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន** ផង ក្នុងឱកាសសម្តេចតេជោ អញ្ជើញមកជួបប្រជុំសំណេះសំណាលជាមួយមន្ត្រីរាជការរដ្ឋបាលឃុំ សង្កាត់ ស្រុក ក្រុង ខេត្តកំពត កាលពីថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៦ និងក៏ជាការឆ្លើយតបតាមសំណូមពររបស់ប្រជាពលរដ្ឋផងដែរ។ ទន្ទឹមនេះ ក៏បានស្នើឲ្យគ្រប់អង្គភាពពាក់ព័ន្ធ ជំរុញការដោះស្រាយបញ្ហាដីធ្លីនៅទីណាដែលកើតមានករណីប្រជាពលរដ្ឋ ឬអតីតបុគ្គលិករាជការ បានរស់នៅយូរឆ្នាំលើដីសារពើភណ្ឌរបស់អង្គភាពខ្លួន ដោយគប្បីលើកមតិស្នើសុំគោលការណ៍ដោះស្រាយពីក្រសួងសាមី និងរាជរដ្ឋាភិបាល ដើម្បីបញ្ចប់បញ្ហារ៉ាំរ៉ៃនេះ សំដៅធ្វើឲ្យប្រជាពលរដ្ឋ ឬអតីតបុគ្គលិករាជការ មានភាពកក់ក្តៅ នឹងនរក្នុងចិត្តលើបញ្ហាដីធ្លី ផ្ទះសម្បែង ដែលពួកគាត់កំពុងរស់នៅ។ កន្លងទៅ សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក៏បានក្រើនរំលឹកបញ្ហានេះផងដែរ ដែលគ្រប់ក្រសួង មន្ទីរ អង្គភាព ត្រូវតែយកចិត្តទុកដាក់អនុវត្តឲ្យបានម៉ឺងម៉ាត់ និងមានតម្លាភាព។

ឯកឧត្តមទេសរដ្ឋមន្ត្រី ដែលជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត បានសង្កត់ធ្ងន់ថា ពេលប្រជាពលរដ្ឋយើងជួបការលំបាក គឺក្រុមការងារយើងត្រូវតែមានមុខជួយពួកគាត់។

មុននឹងបញ្ចប់កិច្ចប្រជុំ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានផ្តាំផ្ញើដល់ក្រុមការងារថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ បន្តជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ក្នុងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតថ្មី ឲ្យបានគ្រប់ៗគ្នា តាមកាលកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

គួរបញ្ជាក់ដែរថា មកដល់ពេលនេះ ក្រុមការងារថ្នាក់ជាតិខេត្តកំពត បានចុះធ្វើវេទិកាសាធារណៈ នៅគ្រប់ឃុំ សង្កាត់ ទូទាំងខេត្តកំពត ដើម្បីស្តាប់សំណូមពរ និងដោះស្រាយបញ្ហាប្រឈមជូនប្រជាពលរដ្ឋ ហើយកំពុងបន្តធ្វើឡើងវិញនៅតាមឃុំ សង្កាត់ទាំងអស់នោះ ក្នុងជុំទី២ តទៅទៀត។

រៀបចំដោយៈ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ













រៀបចំដោយៈ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន